ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្តាល

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខ:៧៦៧អ.ក

ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨

សំណុំរឿងជំនុំជំរះលេខ៖៨៤៣ ជ.រ

ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩

សាលក្រមលេខ:៧១ (ប)

ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០

ដោយមានសមាសភាពដូចតទៅ៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

### តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

### ដើម្បីជំនុំជម្រះ

**លើសំណុំរឿងព្រហ្មទណ្ឌលេខ ៧៦៧ អក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ ដែលមាន៖**

១-ជនជាប់ចោទឈ្មោះ [redacted] ជាទ្ធី ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ នាយកដ្ឋានអង្គរក្សខេត្តកណ្តាល ទីកន្លែងកំណើតភូ[redacted] ខេត្តកំពត និងទីលំនៅបច្ចុប្បន្នភូមិឆ្នាពួន ឃុំដើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រពន្ធឈ្មោះ [redacted] ថាវី មានកូន ០៤ នាក់ ឪពុកឈ្មោះ [redacted] សារុន (ស) ម្តាយឈ្មោះ [redacted] គីមលី (រស់) ទោសពីមុនគ្មាន។ ( ក្រៅឃុំ )

២-ជនជាប់ចោទឈ្មោះ [redacted] សូធី ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើតភូ[redacted] ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្នភូមិឆ្នាពួន ឃុំដើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រពន្ធឈ្មោះ [redacted] កែវមុន្នី មានកូន ០៤ នាក់ ឪពុកឈ្មោះ [redacted] ហ៊ន (រស់) ម្តាយឈ្មោះ [redacted] ណាម (រស់) ទោសពីមុនគ្មាន។ ( ក្រៅឃុំ )

៣-ជនជាប់ចោទឈ្មោះ [redacted] វណ្ណី ភេទប្រុស អាយុ ៤៥ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន[redacted] ខេត្តកណ្តាល ។( ក្រៅឃុំ)

-ជាប់ចោទពីបទៈ ធ្វើឱ្យបាត់ជំនឿលើសេចក្ដីសម្រេចរបស់តុលាការ ប្រព្រឹត្តនៅភូមិឆ្នាពូន ឃុំដើងកើប ស្រុកកណ្ដាល ស្ទឹងខេត្តកណ្ដាល កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ តាមមាត្រា ៥២៣ កថាខណ្ឌ២ នៃក្រមព្រហ្មទណ្ឌ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ មាស សួនី ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] មន ភេទស្រី អាយុ ៧១ឆ្នាំ នៅភូមិឆ្នាពូន ឃុំដើងកើប ស្រុកកណ្ដាល ស្ទឹង ខេត្តកណ្ដាល ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៧៧២ ដកសព ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ៨៥១ ដកបជរ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល។

អង្គហេតុនៃរឿងមានដូចតទៅ៖

កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ ខាងអាជ្ញាសាលាអមសាលាដំបូងខេត្តកណ្ដាល បានចុះអនុវត្តដីកាសម្រេចដីការក្សាការពារលេខ ០២ ដកសរ ដែលក្នុងន័យមិនអនុញ្ញាតឱ្យមានការសាងសង់នៅលើដីកំពុងមានទំនាស់ ដែលស្ថិតនៅភូមិឆ្នាពូន ឃុំដើងកើប ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។ ប៉ុន្តែឈ្មោះ [redacted] ជាន្នី នៅតែបញ្ជាឱ្យឈ្មោះ [redacted] វណ្ណី និងឈ្មោះ [redacted] សួនី សាងសង់ដែលក្រោយមានការចុះអនុវត្តរួច។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ជាន្នី បានឆ្លើយថាដីរបស់ខ្លួនមានទំហំ ២៣ម × ២៧ម ស្ថិតនៅភូមិឆ្នាពូន ឃុំដើងកើប។ដីនេះខ្លួនទិញពីឈ្មោះ [redacted] រុង កាលពីឆ្នាំ២០១០ តម្លៃ ៤៥០០ ដុល្លា។ដីនេះខ្លួនមានលិខិតបញ្ជាក់ពីមេឃុំ និងក្រុមប្រឹក្សា តែពុំមានប័ណ្ណកម្មសិទ្ធិទេ។ នៅឆ្នាំ២០១១ ខ្លួនចាប់ផ្ដើមចាក់ដី។នៅឆ្នាំ២០១៣-២០១៤ ខ្លួនក៏ចាក់ដី ម្ដងទៀត ដោយសារដីត្រូវចាក់កម្ពស់ ២ម៉ែ។នៅឆ្នាំ២០១៧ ខ្លួនចាក់ដីម្ដងទៀត ខ្លួនធ្វើរបងថ្ម និងបាំងសំណាញ់លួស។នៅឆ្នាំ២០១៨ ខ្លួនបានសង់ផ្ទះលើដីនោះជាផ្ទះថ្ម ទំហំ ១៥ម × ២៧ម ។ដីខាងលើនេះខ្លួនបានឱ្យទៅបងប្រុសបង្កើតខ្លួនឈ្មោះ [redacted] ប៊ុនធឿន សង់ផ្ទះដែរ ។នៅពេលធ្វើផ្ទះរួចហើយនៅឆ្នាំ២០១៨ ផ្ទះរបស់បងបង្កើតខ្លួនឈ្មោះ [redacted] ប៊ុនធឿន មានដីកាសម្រេចរក្សាការពារបានហាមឃាត់ និងការអនុវត្តដីការក្សាការពារ ទើបដឹងថាមានទំនាស់។ ខ្លួនមិនស្គាល់ភាគីដើមបណ្ដឹងទេ ដីរបស់ខ្លួននៅលើប្រឡាយ ដែលពេលនោះផ្ទះរបស់ខ្លួនធ្វើបាន ៣០% ហើយបានផ្អាកការសាងសង់នៅឆ្នាំ២០១៨។ ដី និងផ្ទះរបស់ខ្លួនពុំជាប់ក្នុងដីកាសម្រេចរក្សាការពារទេ។ ខ្លួនបានឃើញតុលាការបានអនុវត្តដីការក្សាការពារបិទនៅផ្ទះរបស់បងប្រុសឈ្មោះ [redacted] សួនី នៅឆ្នាំ ២០១៨ ។ឈ្មោះ [redacted] សួនី ខ្លួនស្គាល់ រីឯឈ្មោះ [redacted] វណ្ណី មិនស្គាល់ទេ ហើយខ្លួនពុំបានប្រាប់ឈ្មោះ [redacted] សួនី ឱ្យធ្វើការសាងសង់លើដីជាប់រក្សាការពារទេ។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] សូនី បានឆ្លើយថា ដីខ្លួនមានទំហំ ៣០ម × ៣០ម ស្ថិតនៅភូមិត្នាពួន ឃុំជើងកែប ដែលដីនេះខ្លួនទិញពីឈ្មោះ [redacted] សឿន ទំហំ ១៥ម × ៣០ម និងទិញដីពីឈ្មោះ [redacted] សូម៉ាលី ទំហំ១៥ម × ៣០ម សរុប ៣០ម × ៣០ម មានតំលៃ ៧០០ ដុល្លា ដោយដីនេះមានពីរប្លង់ មានការដឹងឮពីមេភូមិ ហើយដីនេះខ្លួនមិនបានធ្វើប័ណ្ណកម្មទេ ដោយសារខ្លួនខ្វះថវិការ ។ នៅថ្ងៃតុលាការចុះអនុវត្តដីការក្សាការពារ ខ្លួនទៅធ្វើការសំណង់ និងពីរថ្ងៃក្រោយមកផ្ទះវិញទើបដឹងថា តុលាការអនុវត្តដីការក្សាការពារហាមឃាត់មិនឲ្យសាងសង់បន្ថែមទេ ខ្លួនមិនបានធ្វើទេ និងឈ្មោះ [redacted] វណ្ណីខ្លួនពុំស្គាល់ និងឈ្មោះ [redacted] ផាន្នី ខ្លួនស្គាល់ ដែលគាត់ជួលខ្លួនទៅធ្វើផ្ទះនៅលើដីគាត់ខាងជើងផ្សេងពីដីទំនាស់រក្សាការពារ ។ ដីមានរក្សាការពារមានដីខ្លួននិងប្រពន្ធខ្លួនឈ្មោះ [redacted] កែវមុន្នី ។ខ្លួនបានសង់ផ្ទះឈើលើថ្មខាងក្រោម ទទឹង ១០ម × បណ្តោយ ១៥ម នៅឆ្នាំ២០០៥ គឺទិញហើយធ្វើផ្ទះតែម្តង ពេលខ្លួនទិញ ដីនេះពុំមានទំនាស់ទេ ឆ្នាំ២០១៨ ទើបដឹងថាមានទំនាស់ ។ខ្លួនបានឃើញដីកាសម្រេចរក្សាការពារបិទនៅលើផ្ទះឈ្មោះ [redacted] ប៊ុនធឿន ដែលត្រូវជាបងប្រុសបង្កើតរបស់ឈ្មោះ [redacted] ផាន្នី ឆ្នាំ២០១៨។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មន បានឆ្លើយថា ដីរបស់ខ្លួនមានទំហំកន្លះហិចតាទទឹងជាង ៥០ម និងបណ្តោយប្រហែល ១០០ម ព្រោះដីនេះខ្លួនទិញពីឈ្មោះ [redacted] សុផល ប្រពន្ធឈ្មោះ [redacted] ម៉ុត ទិញនៅឆ្នាំ ១៩៩១ ដោយមានប្រធានភូមិឈ្មោះ [redacted] ម៉ៅ ជាអ្នកដឹងឮចុះហត្ថលេខា។ ដីនេះមិនទាន់ធ្វើប័ណ្ណកម្មសិទ្ធិទេ ហើយដីនេះពុំមានដាំបង្គោលព្រំទេ ហើយអត់ធ្វើផ្ទះដែរ ជាដីស្រែ។នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ មានការចុះអនុវត្តដីការក្សាការពារដោយហាមឃាត់មិនឲ្យសាងសង់លើដីទំនាស់ ប៉ុន្តែឈ្មោះ [redacted] វណ្ណី ,ឈ្មោះ [redacted] សូនី និងឈ្មោះ [redacted] ផាន្នី បន្តធ្វើការសាងសង់លើដីទំនាស់ទៀត ពុំបានគោរពតាមច្បាប់ទេ ដោយហេតុថា ដីនេះខ្លួនលក់ឲ្យក្រុមហ៊ុនឈ្មោះ [redacted] ចាន់ហេង ទាំងខ្ទង់ទំនប់សរុបទៅទំហំ ៣០០០ ម២ នៅសល់ដីជិត២០០០ម២ ដែលមានទទឹង៦៦ម និងបណ្តោយ ៣០ម។ ដីនេះជាប់ស្ទឹងតាហោ ហើយខ្លួនធ្វើស្រែរហូតឆ្នាំ ២០០៥។ ឈ្មោះ [redacted] សូនី និងឈ្មោះ [redacted] ផាន្នី ទិញក្រោយខ្លួនទេ ជាន់ដីរបស់ខ្លួន ក៏ឈ្មោះ [redacted] វណ្ណី ជាជាងធ្វើផ្ទះឲ្យឈ្មោះ [redacted] ផាន្នី។ ដីកាសម្រេចរក្សាការពារចេញនៅឆ្នាំ ២០១៨ ហើយមានសាលក្រមផង។ខ្លួនទាមទារជម្ងឺចិត្ត និងការខាតបង់ពេលវេលាសរុបចំនួន១៥០០០ ដុល្លាពីជនជាប់ទាំងបីនាក់ និងឲ្យផ្តន្ទាទោសតាមច្បាប់ ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ក្រោយពីបានពិនិត្យសំណុំរឿង ដែលមានជនជាប់ចោទឈ្មោះ [redacted] ផាន្នី ,ឈ្មោះ [redacted] សូនី និងឈ្មោះ [redacted] វណ្ណី ពីបទ ធ្វើឲ្យបាត់ជំនឿសេចក្តីសម្រេចរបស់តុលាការ។ បន្ទាប់ពីបានស្តាប់ចម្លើយជនជាប់ចោទ ,ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ,តំណាងអយ្យការ ស្នើសុំតុលាការពិនិត្យឯកសារពាក់ព័ន្ធ និងសម្រេចសេចក្តីទៅតាមច្បាប់។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា: យោងតាមដីកាសម្រេចរក្សាការពារលេខ ០២ ដកសរ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ បានហាមឃាត់ឈ្មោះ [redacted] សូនី ប្រពន្ធឈ្មោះ [redacted] កែវមុនី ,ឈ្មោះ [redacted] សឿន ,ឈ្មោះ [redacted] ផាន់ណាក់ ប្រពន្ធឈ្មោះ [redacted] សឿន និងឈ្មោះ [redacted] គីមឡេង មិនឲ្យលក់ដូរ ជួល បញ្ចាំ ធ្វើអំណោយ

ឬមរតក ដាក់ធានា ដាក់ហ៊ីប៉ូតែក ផ្ទេរកម្មសិទ្ធិ ប្រទានកម្ម ទៅឲ្យអ្នកដទៃ និងមិនឲ្យសាងសង់សំណង់ផ្សេងៗលើដីមានទំហំ ២០០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិត្នោតពូន ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ ក៏ប៉ុន្តែនៅក្នុងដីកាសម្រេចរក្សាការពារពុំបានហាមឃាត់ឈ្មោះ [redacted] ផានី ទេ ហេតុនេះពុំមានចំណុចណាដែលបញ្ជាក់ថាឈ្មោះ [redacted] ផានី ធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការនោះទេ ហើយម្យ៉ាងទៀតទាក់ទងនឹងព្រំប្រទល់ដីគឺបានឆ្លើយខុសព្រំប្រទល់ដី ស្នើសុំតុលាការលើកលែងចោទប្រកាន់លើឈ្មោះ [redacted] ផានី និងឈ្មោះ [redacted] សួនី។

+ជនជាប់ចោទឈ្មោះ [redacted] ផានី និយាយសំដីចុងក្រោយ ៖មានសំណូមពរឲ្យតុលាការជួយរកយុត្តិធម៌

+ជនជាប់ចោទឈ្មោះ [redacted] សួនី និយាយសំដីចុងក្រោយ៖ មានសំណូមពរឲ្យតុលាការជួយរកយុត្តិធម៌

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាង

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌ ពីចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ដែលមានជនជាប់ចោទឈ្មោះ [redacted] វណ្ណី ភេទប្រុស អាយុ ៤៥ឆ្នាំ ,ឈ្មោះ [redacted] ផានី ភេទប្រុស អាយុ ៣៥ឆ្នាំ និងឈ្មោះ [redacted] សួនី ភេទប្រុស អាយុ ៥២ឆ្នាំ ពីបទៈ ធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំ ជម្រះលេខ ៨៥១ ដក.បជរ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ តុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទ យោងតាមមាត្រា ២៨៩ ,មាត្រា ២៩១ និងមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យោងតាមចម្លើយជនជាប់ចោទ ,ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងឃើញថា ដីកាសម្រេចរក្សាការពារលេខ ០២ ដកសរ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកណ្តាល បានហាមឃាត់ឈ្មោះ [redacted] សួនី ប្រពន្ធឈ្មោះ [redacted] កែវមុនី ,ឈ្មោះ [redacted] សឿន ,ឈ្មោះ [redacted] ផាន់ណាក់ ប្រពន្ធឈ្មោះ [redacted] សឿន និងឈ្មោះ [redacted] គីមឡេង មិនឲ្យលក់ដូរ ជួល បញ្ចាំ ធ្វើអំណោយ ឬមរតក ដាក់ធានា ដាក់ហ៊ីប៉ូតែក ផ្ទេរកម្មសិទ្ធិ ប្រទានកម្ម ទៅឲ្យអ្នកដទៃ និងមិនឲ្យសាងសង់សំណង់ផ្សេងៗលើដីមានទំហំ ២០០០ ម$^2$ ស្ថិតនៅភូមិត្នោតពូន ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ ដីកាសម្រេចរក្សាការពារនេះត្រូវបានអនុវត្តចប់សព្វគ្រប់តាមកំណត់ហេតុអនុវត្តចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ ។ក៏ប៉ុន្តែឈ្មោះ [redacted] សួនី មិនអនុវត្តតាមសេចក្តីសម្រេចតុលាការនេះទេ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សួនី គឺជាអង្គហេតុត្រូវនឹងធាតុផ្សំបទល្មើសធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ ដែលលមានចែងតាម

ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ តាមមាត្រា ៥២៣ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

២-ឲ្យឈ្មោះ [redacted] វណ្ណី ភេទប្រុស អាយុ ៤៥ឆ្នាំ ,ឈ្មោះ [redacted] ផាន្នី ភេទប្រុស អាយុ ៣៥ឆ្នាំ រួចខ្លួនពីបទចោទៈ ធ្វើឲ្យបាត់ជំនឿលើសេចក្ដីសម្រេចរបស់តុលាការ ប្រព្រឹត្តនៅភូមិធ្លាពូន ឃុំជើងកើប ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០១៨ តាមមាត្រា ៥២៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-បង្គាប់ឲ្យឈ្មោះ [redacted] សុទ្ធី ផ្ដល់សំណងទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] មន ចំនួន ៦០០០០០០ (ប្រាំមួយលាន) រៀល ការទាមទារលើសពីនេះត្រូវច្រានចោល ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុទ្ធី, ចំពោះមុខឈ្មោះ [redacted] ផាន្នី ,ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] មន ,កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] វណ្ណី និងប្រកាសជាសាធារណៈនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ រក្សាសិទ្ធិប្ដឹងទាស់ ឬ ប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ក្រឡាបញ្ជី
ហត្ថលេខា និងត្រា [redacted]

ចៅក្រមជំនុំជម្រះ
ហត្ថលេខា និងត្រា [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃសុក្រ ៧ រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ខេត្តកណ្ដាល,ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០
**ក្រឡាបញ្ជី**

[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**

[redacted]